**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួង កិច្ចការនារី**

លេខ ......០០១..... កកន/ប្រក

## ប្រកាស
## ស្តីពី
## ការបង្កើតការិយាល័យចំណុះមន្ទីរកិច្ចការនារី ខេត្ត-ក្រុង

## រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងតាមសំណូមពរការងារចាំបាច់ ។

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតមន្ទីរកិច្ចការនារី ខេត្ត - ក្រុងជាពីរប្រភេទ សំរាប់ទទួលបន្ទុកអនុវត្ត និងសំរបសំរួលសកម្មភាពរបស់ក្រសួងដែលបានកំណត់តាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី ។

១ - ប្រភេទ " ក " សំរាប់ខេត្ត ទាំង ១៣ គឺ ខេត្តកណ្ដាល, ខេត្តកំពង់ស្ពឺ, ខេត្តតាកែវ, ខេត្តកំពង់ឆ្នាំង . ខេត្តព្រៃវែង, ខេត្តកំពង់ចាម, ខេត្តស្វាយរៀង, ខេត្តកំពត, ខេត្តពោធិសាត់, ខេត្តបាត់ដំបង, ខេត្តបន្ទាយមានជ័យ, ខេត្តសៀមរាប និងខេត្តកំពង់ធំ ។

២ - ប្រភេទ " ខ " សំរាប់ខេត្ត -ក្រុងទាំង ១១ គឺ រាជធានីភ្នំពេញ, ក្រុងប៉ៃលិន, ក្រុងព្រះសីហនុ, ក្រុងកែប, ខេត្តឧត្ដរមានជ័យ, ខេត្តព្រះវិហារ, ខេត្តស្ទឹងត្រែង, ខេត្តក្រចេះ, ខេត្តរតនៈគីរី, ខេត្តមណ្ឌលគីរី និងខេត្តកោះកុង ។

**ប្រការ ២ :** មន្ទីរកិច្ចការនារី ខេត្ត-ក្រុងទាំងពីរប្រភេទ ( ដូចប្រការ ១ ) មានរចនាសម្ព័ន្ធដូចខាងក្រោម :

ក. មន្ទីរកិច្ចការនារីប្រភេទ " ក " មាន ០៨ ការិយាល័យ :

១- ការិយាល័យរដ្ឋបាល-បុគ្គលិក

២- ការិយាល័យហិរញ្ញវត្ថុ និងផ្គត់ផ្គង់

៣- ការិយាល័យផែនការ និងស្ថិតិ

៤- ការិយាល័យសមភាពយេនឌ័រ

៥- ការិយាល័យ ព័ត៌មាន

៦- ការិយាល័យអភិវឌ្ឍសេដ្ឋកិច្ច

៧- ការិយាល័យការពារផ្លូវច្បាប់

៨- ការិយាល័យស្ត្រី និងសុខភាព-ស្ត្រី និងការអប់រំ

ខ. មន្ទីរកិច្ចការនារីប្រភេទ " ខ " មាន ០៦ ការិយាល័យ :

១- ការិយាល័យរដ្ឋបាល-បុគ្គលិក

២- ការិយាល័យហិរញ្ញវត្ថុ និងផ្គត់ផ្គង់ -ផែនការ និងស្ថិតិ

៣- ការិយាល័យសមភាពយេនឌ័រ និងព័ត៌មាន

៤- ការិយាល័យអភិវឌ្ឍសេដ្ឋកិច្ច

៥- ការិយាល័យការពារផ្លូវច្បាប់

៦- ការិយាល័យស្ត្រី និងសុខភាព -ស្ត្រី និងការអប់រំ

**ប្រការ ៣ :** តួនាទី ភារកិច្ចជាក់ស្ដែងរបស់ការិយាល័យនីមួយៗ អាស្រ័យដោយអង្គភាពពាក់ព័ន្ធរៀបចំឡើង និង លើកសំណើជូនរដ្ឋមន្ត្រីពិនិត្យ សំរេច ក្រោយពីបានទទួលឯកភាពពី អគ្គនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ។

**ប្រការ ៤ :** ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៥ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦ :** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ប្រធាននាយកដ្ឋានរដ្ឋបាល-បុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ គ្រប់ប្រធានមន្ទីរកិច្ចការនារីខេត្ត-ក្រុងត្រូវអនុវត្ត តាមប្រកាសនេះ ដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៦

រដ្ឋមន្ត្រី

អ៊ឹង កន្ថាផាវី

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដូចប្រការ ៦
- ឯកសារ -កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ០០១ កកន/ប្រក ចុះថ្ងៃទី១០ ខែ មករា ឆ្នាំ ២០០៦

អង្គការលេខរបស់មន្ទីរកិច្ចការនារីខេត្ត-ក្រុង ( ប្រភេទ ក )



ឧបសម្ព័ន្ធនៃប្រកាសលេខ ០០១ កកន/ប្រក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៦

អង្គការលេខរបស់មន្ទីរកិច្ចការនារីខេត្ត-ក្រុង ( ប្រភេទ ខ )

